**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ :** ០១ ប្រក.ព

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅព្រឹកថ្ងៃសុក្រ ១កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង៨ និង៣០នាទីព្រឹក នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើៈ

**១- សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត។**

**២-គម្រោងវិនិយោគវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ទំហំ ៨០MW និងគម្រោងវិនិយោគស្ថានីយអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ២កន្លែង នៅពោធិ៍សាត់១កន្លែង ៦០MW និងនៅកំពង់ឆ្នាំង១កន្លែង ៦០MW និងបន្ថែមអានុភាព ២០MW លើគម្រោងផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ៦០MW នៅកំពង់ស្ពឺដែលបានអនុម័តរួច ដើម្បីផលិតអគ្គិសនីលក់ឱ្យអគ្គិសនីកម្ពុជា។**

**៣-សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីសុខភាពសិក្សា។**

**៤-បញ្ហាផ្សេងៗៈ**

សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើៈ

៤.១.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ស្ដីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ។

៤.២.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ាត ស្ដីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ។

៤.៣.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋតួគី ស្ដីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ។

៤.៤.កិច្ចព្រមព្រៀងស្ដីពីការបង្កើតអង្គការបណ្ដាញអន្តរជាតិសម្រាប់ឫស្សី និងផ្ដៅ។

ក្រោយពីបានស្ដាប់របាយការណ៍ នឹងមតិពិភាក្សាផ្លាស់ប្ដូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័តៈ

**១-សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត**

សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត គឺជាច្បាប់ដែលមានភាពចាំបាច់បំផុតក្នុងការគ្រប់គ្រងនិងអភិវឌ្ឍធនធានប្រេងកាតក្នុងព្រះរាជាណាចក្រកម្ពុជា។ សេចក្ដីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃវិស័យប្រេងកាតក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ច

សង្គម និងបរិស្ថាន ពិសេសក្នុងគោលបំណងជំរុញអភិវឌ្ឍវិស័យប្រេងកាតប្រកបដោយនិរន្តរភាពនិងប្រសិទ្ធភាព ដើម្បីរួមចំណែកអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គម និងផលប្រយោជន៍យូរអង្វែងរបស់ប្រទេសជាតិ ស្របពេលដែលបច្ចុប្បន្នការស្វែងរុករកនិងការអភិវឌ្ឍធនធានប្រេងកាតទាំងដែនគោក និងសមុទ្របាននិងកំពុងដំណើរការទៅមុខ ដោយក្នុងនោះប្លុកប្រេងកាតមួយនៅដែនសមុទ្រកំពុងឈានទៅរកការបូមយកប្រេងលើកទីមួយក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជានាឆ្នាំខាងមុខនេះ។ សេចក្តីព្រាងច្បាប់នេះ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពក្នុងវិស័យប្រេងកាត នៅក្នុងបូរណភាពទឹកដីនិងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។

ការគ្រប់គ្រងវិស័យប្រេងកាត ត្រូវផ្អែកលើគោលការណ៍តម្លាភាព គណនេយ្យភាព សមធម៌ក្នុងវឌ្ឍនភាពសង្គមនិងសុខុមាលភាពសាធារណៈ សន្តិសុខនិងសុវត្ថិភាព និងការទទួលខុសត្រូវបរិស្ថាន។ ដើម្បីអនុវត្តគោលការណ៍នេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ការគ្រប់គ្រងវិស័យប្រេងកាតត្រូវធានាឱ្យបាននូវៈ ១.ផលប្រយោជន៍ជាតិជាអតិបរមា ២.ឧត្តមានុវត្តក្នុងសកម្មភាពផ្នែកអាប់ស្ទ្រីមនិងដោនស្ទ្រីម ៣.ការផ្គត់ផ្គង់ផលិតផលប្រេងកាតប្រកបដោយគុណភាព បរិមាណ និងតម្លៃ ដែលរួមចំណែកដល់ការពង្រឹងសន្តិសុខថាមពលជាតិ ៤.ការទទួលខុសត្រូវខ្ពស់ផ្នែកបរិស្ថាន ៥.ការកសាង ជំរុញ និងលើកតម្កើងសមត្ថភាពជាតិទាំងផ្នែកបច្ចេកទេសនិងធុរកិច្ចក្នុងវិស័យប្រេងកាត ៦.ការបង្កើតឱកាសការងារដល់ប្រជាពលរដ្ឋនិងសេវាកម្មក្នុងស្រុក ៧.ការបង្កើនចំណូលថវិកាជាតិ និង ៨.ការបង្កើតផលប្រយោជន៍ផ្ទាល់ដល់សហគមន៍មូលដ្ឋាន និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋក្នុងតំបន់ប្រតិបត្តិការប្រេងកាត។

តាមរយៈគោលបំណងខាងលើនេះ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត ត្រូវបានរៀបចំឡើងដោយមាន៩ជំពូក និង៧២មាត្រា។

**២-គម្រោងវិនិយោគវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ទំហំ ៨០MW និងគម្រោងវិនិយោគ ស្ថានីយអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ២កន្លែង នៅពោធិ៍សាត់១កន្លែង ៦០MW និងនៅកំពង់ឆ្នាំង ១កន្លែង ៦០MW និងបន្ថែមអានុភាព ២០MW លើគម្រោងផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ៦០MW នៅកំពង់ស្ពឺដែលបានអនុម័តរួច ដើម្បីផលិតអគ្គិសនីលក់ឱ្យអគ្គិសនីកម្ពុជា**

រាជរដ្ឋាភិបាលបានអនុម័តឱ្យក្រុមហ៊ុន SPHP (Cambodia) Co., Ltd. ធ្វើការវិនិយោគលើគម្រោងវារីអគ្គិសនីពោធិ៍សាត់១ ដែលមានទំហំ៨០មេហ្គាវ៉ាត់ និងក្រុមហ៊ុន Schnei Tec Co., Ltd. ធ្វើការវិនិយោគលើគម្រោងស្ថានីយអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ២កន្លែង នៅខេត្តពោធិ៍សាត់មួយកន្លែង៦០មេហ្គាវ៉ាត់ និងមួយកន្លែងទៀត៦០មេហ្គាវ៉ាត់នៅខេត្តកំពង់ឆ្នាំង និងបន្ថែមអានុភាព២០មេហ្គាវ៉ាត់ លើគម្រោងផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ៦០មេហ្គាវ៉ាត់នៅកំពង់ស្ពឺ ដែលបានអនុម័តរួច ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអគ្គិសនីនៅកម្ពុជា។

គម្រោងវិនិយោគសាងសង់ស្ថានីយវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ មានអានុភាព៨០មេហ្គាវ៉ាត់ ស្ថិតនៅឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ នឹងត្រូវវិនិយោគក្រោមរូបភាព សាងសង់-ដំណើរការ-ផ្ទេរ (BOT) ដោយត្រូវចំណាយទុនវិនិយោគ ២៣១,១០ លានដុល្លារសហរដ្ឋអាមេរិក សម្រាប់រយៈពេលសម្បទាន ៣៩ឆ្នាំ។ គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ចំពោះប្រទេសកម្ពុជា ទាំងលក្ខណៈបច្ចេកទេស សេដ្ឋកិច្ច និងសង្គម ជាអាទិ៍កម្ពុជានឹងទទួលបានប្រភពអគ្គិសនីពីធនធានធម្មជាតិក្នុងស្រុក កាត់បន្ថយការប្រើប្រាស់ប្រេងឥន្ធនៈដែលមានថ្លៃខ្ពស់ ធានានូវសន្តិសុខថាមពល និងអគ្គិសនីមានថ្លៃសមរម្យ។ គម្រោងនេះនឹងសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈបន្ថែមទៀត ដោះស្រាយផលប៉ះពាល់បរិស្ថាននិងសង្គម មិនតែ

ប៉ុណ្ណោះផ្តល់ការងារដល់ប្រជាពលរដ្ឋរាប់ពាន់នាក់ក្នុងអំឡុងពេលសាងសង់ បង្កើនគុណតម្លៃអេកូទេសចរណ៍ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនៅមូលដ្ឋាន ពិសេសផ្តល់ចំណូលពន្ធសរុបប្រមាណ ២,៩២លានដុល្លាអាមេរិកក្នុង១ឆ្នាំ ដោយមិនទាន់គិតដល់ពន្ធដទៃទៀត និងពន្ធលើអ្នកចែកចាយអគ្គិសនីលក់បន្ត។

គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ស្ថិតនៅស្រុកក្រគរ ខេត្តពោធិ៍សាត់ មានអានុភាព៦០មេហ្គាវ៉ាត់ និងគម្រោងមួយទៀតស្ថិតនៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង មានអានុភាព៦០ មេហ្គាវ៉ាត់។ គម្រោងទាំងពីរនេះធ្វើឡើងក្នុងរូបភាពជាគម្រោងវិនិយោគ សាងសង់-ធ្វើជាម្ចាស់-ដំណើរការខ្លួនឯង (BOO) ក្នុងរយៈពេលអាជីវកម្ម២០ឆ្នាំ ដោយចំណាយទុនវិនិយោគ ៥៨ ២២៥ ៣២០ ដុល្លាសហរដ្ឋអាមេរិកក្នុងមួយទីតាំង។ គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ប្រទេសកម្ពុជា ជាអាទិ៍កម្ពុជានឹងទទួលបានអគ្គិសនីពីប្រភពថាមពលកកើតឡើងវិញដែលមានអានុភាពធំ កាត់បន្ថយការប្រើប្រាស់ប្រេងឥន្ធនៈដែលមានតម្លៃខ្ពស់ បន្ថែមបរិមាណផលិតកម្មអគ្គិសនីដែលធានាបាននូវសន្តិសុខថាមពលក្នុងការផ្គត់ផ្គង់អគ្គិសនីមានគុណភាពនិងមានតម្លៃសមរម្យ ពិសេសជួយបំពេញនូវកង្វះខាតអគ្គិសនីក្នុងរដូវប្រាំង។ គម្រោងនេះនឹងផ្តល់ការងារជូនប្រជាពលរដ្ឋ នាំមកនូវបច្ចេកវិទ្យាថ្មីៗ និងផ្តល់ពន្ធចំណូលជូនរដ្ឋ ដែលជាមធ្យមទទួលបាន ៥៦៨ ៣៧៤ ដុល្លាសហរដ្ឋអាមេរិកក្នុង១ឆ្នាំពីទីតាំងខេត្តនីមួយៗ ដោយមិនទាន់គិតពន្ធដទៃទៀត និងពន្ធលើអ្នកចែកចាយអគ្គិសនីលក់បន្ត។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តការបន្ថែមអានុភាព២០មេហ្គាវ៉ាត់ លើគម្រោងវិនិយោគរបស់ក្រុមហ៊ុន Schnei Tec Co., Ltd. ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាលអាណត្តិមុន លើការផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ៦០មេហ្គាវ៉ាត់ នៅត្បាតពង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ សរុប៨០មេហ្គាវ៉ាត់។ ដើម្បីឆ្លើយតបនឹងសភាពការណ៍បច្ចុប្បន្នដែលប្រទេសកម្ពុជាកំពុងមានការខ្វះខាតអគ្គិសនីសម្រាប់ផ្គត់ផ្គង់ រាជរដ្ឋាភិបាលបានអនុម័តការបន្ថែមអានុភាព ដោយសារពិនិត្យឃើញពីភាពជោគជ័យនៃការអនុវត្តគម្រោងនេះក្នុងជំហានទី១ ២០មេហ្គាវ៉ាត់ និងអាចដំណើរការជំហានទី២ និងទី៣ជាបន្តបន្ទាប់បាន ខណៈដែលទីតាំងគម្រោងនេះនៅសល់ផ្ទៃដីអាចតម្លើងបន្ថែម២០មេហ្គាវ៉ាត់ទៀតបាន។ ការបន្ថែមអានុភាព២០មេហ្គាវ៉ាត់នេះ ជាកាលានុវត្តភាពថ្មីនៃការផ្តល់ប្រភពបន្ថែមដែលមានថ្លៃទាប និងអាចដាក់ឱ្យដំណើរការបានឆាប់រហ័ស។

## ៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសុខភាពសិក្សា

សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសុខភាពសិក្សា មានចក្ខុវិស័យអភិវឌ្ឍធនធានមនុស្សឲ្យមានលក្ខណៈសម្បត្តិពេញលេញនិងមានសុខភាពល្អ ទាំងកាយសម្បទា ទាំងបញ្ញា ទាំងស្មារតី ដើម្បីអភិវឌ្ឍសង្គមកម្ពុជាប្រកបដោយចីរភាព។ សេចក្តីព្រាងគោលនយោបាយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងរួមចំណែកលើកកម្ពស់គុណភាពអប់រំ និងផ្តល់ឲ្យអ្នកសិក្សានិងបុគ្គលិកអប់រំនូវលទ្ធភាពក្នុងការទទួលបាននូវសុខភាពល្អនិងសុខុមាលភាព ដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្តានុពល។ សេចក្តីព្រាងគោលនយោបាយនេះនឹងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជាៈ ទី១.ធានាបាននូវការសិក្សាប្រកបដោយគុណភាពនិងបង្កើនអត្រាបញ្ចប់ការសិក្សា និងអត្រាគង់វង្សរបស់សិស្សក្នុងការសិក្សា ទី២.ជាយន្តការចូលរួមពង្រឹងនិងពង្រីកសេវាលើកកម្ពស់សុខភាពជូនដល់អ្នកសិក្សាបុគ្គលិកអប់រំ និងប្រជាពលរដ្ឋទូទៅ ដោយផ្តើមចេញពីសាលារៀន និងទី៣.កាត់បន្ថយចំណាយសេវាសុខាភិបាល និងបង្កើនប្រាក់សន្សំ ដើម្បីសម្រេចចក្ខុវិស័យឆ្នាំ២០៣០ដែលរាជរដ្ឋាភិបាលចង់ប្រែក្លាយប្រទេសកម្ពុជា ជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងប្រែក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ខាងមុខ។ ដើម្បីសម្រេចចក្ខុវិស័យនិងគោលបំណងខាងលើ សេចក្តីព្រាងគោលនយោបាយនេះបានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនរួមមាន ទី១.អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ ទី២.លើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សានិង

បុគ្គលិកអប់រំ ទី៣.លើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ ទី៤.លើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ទី៥.លើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព ទី៦.លើកកម្ពស់ការអប់រំសុខភាព ទី៧.លើកកម្ពស់ការអនុវត្តបំណិនសុខភាព និង ទី៨.លើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពសិក្សា។

**៤-បញ្ហាផ្សេងៗ៖**

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តបញ្ជូន ១.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ ២.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ាត ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ ៣.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋតួគី ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ និង ៤.កិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការបណ្តាញអន្តរជាតិសម្រាប់ឫស្សី និងផ្តៅ ទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ដែលនឹងឈានចូលក្នុងពេលខាងមុខ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជូនពរដល់ជនរួមជាតិខ្មែរគ្រប់រូបដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស មន្ត្រីរាជការ នាយទាហាន ពលទាហាននៃកងយុទ្ធពលខេមរភូមិន្ទដែលបាននិងកំពុងបំពេញភារកិច្ចការពារអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងកំពុងបំពេញបេសកកម្មរក្សាសន្តិភាពនិងមនុស្សធម៌នៅក្រៅប្រទេស នាយនគរបាល ពលនគរបាល ដែលបាននិងកំពុងរួមចំណែកការពារបូរណភាពទឹកដី និងថែរក្សាការពារសន្តិភាព សន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៃមាតុភូមិ ក្មួយៗសិស្សានុសិស្ស និស្សិត យុវជន យុវនារី កម្មករ និយោជិត ធុរជន និងវិនិយោគិនដែលបាននិងកំពុងប្រកបធុរកិច្ចនៅលើទឹកដីកម្ពុជា សូមទទួលបាននូវជោគជ័យ សិរីសួស្តី ជ័យមង្គល និងវិបុលសុខ ជារៀងដរាបតទៅ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១ និង៤៥នាទី។

ថ្ងៃសុក្រ ១កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩